**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រដ្ឋបាលព្រៃឈើ
នាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ

ភ្នំពេញ ថ្ងៃទី ខែមេសា ឆ្នាំ២០១៤

ក្រុមការងារ វាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV)

**សូមគោរពជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ**

**តាមរយៈ:** ប្រធាននាយកដ្ឋានព្រៃឈើ និង សហគមន៍ព្រៃឈើ

**កម្មវត្ថុ:** របាយការណ៍ស្តីពីលទ្ធផលអង្គប្រជុំបច្ចេកទេសវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់(MRV) លើកទី៦។

**ជូនភ្ជាប់:** -រូបថតសកម្មភាពនៃកិច្ចប្រជុំ.......................................................................................ចំនួន១ច្បាប់

-បញ្ជីវត្តមាន....................................................................................................ចំនួន១ច្បាប់

ន័យដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ យើងខ្ញុំសូមអនុញ្ញាតជម្រាបជូនឯកឧត្តមប្រតិភូមេត្តាជ្រាបថា កាលពីថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ ក្រុមការងារបច្ចេកទេស វាស់វែង រាយការណ៍ និង ផ្ទៀងផ្ទាត់ (MRV) បានរៀបចំកិច្ចប្រជុំលើកទី៦ នៅសាលប្រជុំរដ្ឋបាលព្រៃឈើ ជាន់ទី១ ដែលទទួលបានលទ្ធផលដូចខាងក្រោម៖

## I-សមាសភាពចូលរួម

កិច្ចប្រជុំនេះមានសមាជិកចូលរួមចំនួន ០៥ នាក់ (ដូចបញ្ជីវត្តមាននៃឯកសារជូនភ្ជាប់) មកពី៖

-រាជរដ្ឋាភិបាលៈ រដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន

-ក្រុមប្រឹក្សាយោបល់ៈ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAO) ។

## II-គោលបំណងនៃអង្គប្រជុំ

គោលបំណងនៃអង្គប្រជុំធ្វើការពិភាក្សាលើសេចក្តីព្រាងផែនការសកម្មភាព REL/MRV ។

## III-ដំណើរការកិច្ចប្រជុំ

អង្គប្រជុំបានបន្តធ្វើការពិភាក្សាលើសេចក្តីព្រាងផែនការសកម្មភាព REL/MRV ដោយចាប់ផ្តើមពិភាក្សាពីចំណុច៤.៦ ដែលស្តីអំពីការបង្កើតប្រព័ន្ធរាយការណ៍រេដ+មួយដែលទាក់ទងទៅនឹងឧស្ម័នផ្ទះកញ្ចក់។

## IV-លទ្ធផលនៃកិច្ចប្រជុំ

ក្រុមការងារបានបញ្ចប់រៀបចំលើចំណុច ៤.៦ នៃផែនការសកម្មភាពការងារ REL/MRV។ ជារួមក្រុមការងារបានបញ្ចប់ការរៀបចំនូវសេចក្តីព្រាងផែនការសកម្មភាពការងារសម្រាប់ឆ្នាំ២០១៤ ទាំងស្រុង ហើយនឹងពិនិត្យឡើងវិញនាកិច្ចប្រជុំពេលក្រោយ ដើម្បីឈានទៅរកការបញ្ចប់ជាស្ថាពរ ។

V-**ទិសដៅអនុវត្តបន្ត**

ក្រុមការងារនឹងរៀបចំកិច្ចប្រជុំលើកទី៧ នាថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៤ ក្នុងគោលបំណងធ្វើការពិនិត្យឡើងវិញលើសេចក្តីព្រាងផែនការសកម្មភាព REL/MRV មុននឹងដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រតិភូមេត្តាជ្រាបជាសេចក្តីរាយការណ៍ ដោយអនុគ្រោះតាមការគួរ ។

លេខ…………………..នពស

បានឃើញ និង បញ្ជូនមក

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល

ទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ

"សូមមេត្តាជ្រាបជាសេចក្តីរាយការណ៍ ដោយអនុគ្រោះ "

ភ្នំពេញ ថ្ងៃទី ខែមេសា ឆ្នាំ២០១៤

**ប្រធាននាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ**

# រូបថតសកម្មភាពនៃកិច្ចប្រជុំ MRV លើកទី៦



